# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
លេខ : ១២៧/២៤ ក.ប/សរ.ណា.ន.៣.៩

# សេចក្តីណែនាំ
## ស្តីពី
## ការរៀបចំទិវាសម្អាតពិភពលោកលើកទី៧ ( 7th World Cleanup Day )

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាយក នាយិកាគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ លោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានទាំងអស់ជ្រាបថា ដើម្បីរួមចំណែកជាមួយពិភពលោកក្នុងការសម្អាតបរិស្ថាន លើកកម្ពស់ការយល់ដឹង និងចូលរួមក្នុងការគ្រប់គ្រងសំរាម សំណល់រឹងនៅប្រទេសកម្ពុជា ដែលនឹងប្រព្រឹត្តទៅនៅ**ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៤** ក្រសួងសូមធ្វើការណែនាំ ដូចខាងក្រោម៖

- ធ្វើការផ្សព្វផ្សាយ និងចាត់តាំងរៀបចំទិវាសម្អាតពិភពលោកលើកទី៧ ដោយធ្វើអនាម័យសម្អាតសំរាមដំណាលគ្នានៅតាមមូលដ្ឋានរៀងៗខ្លួន ដើម្បីធានាបានបរិស្ថាន និងបរិយាកាសនៅកន្លែងធ្វើការស្អាត បង្កើនប្រសិទ្ធភាព ផលិតភាពការងារ ការរស់នៅស្អាត និងបរិស្ថានបៃតង
- សហការចូលរួមជាមួយអាជ្ញាធរពាក់ព័ន្ធ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតឱ្យបានផុសផុល
- ត្រូវសិក្សាកំណត់ចំនួនគោលដៅ និងទីតាំងអាទិភាពសមស្របសម្រាប់សម្អាត និងបញ្ជ្រាបការយល់ដឹង
- ត្រូវប្រើប្រាស់ស្រោមដៃ និងដង្កៀបចាប់សំរាម និងត្រូវពាក់ម៉ាស់ឱ្យបានជាប់ជានិច្ចក្នុងពេលសម្អាតអនាម័យ ព្រមទាំងមិនត្រូវយកដៃប៉ះពាល់ផ្ទៃមុខរបស់ខ្លួន ប្រសិនបើមិនទាន់បានលាងសម្អាតទេនោះ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា ឯកឧត្តម លោកជំទាវ លោក លោកស្រី នាយក នាយិកាគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ លោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានទាំងអស់ នឹងអនុវត្តតាមខ្លឹមសារសេចក្តីណែនាំនេះប្រកបដោយប្រសិទ្ធភាពក្នុងស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃសុក្រ ៣ រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**ហេង សួរ**

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានការងារ
- គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ